

# អនុស្សាវរីយ៍៣៤ឆ្នាំ

ឈរនៅលើទីមួយខ្ពស់បន្តិច ខ្ញុំទទួលបានភាពត្រជាក់ស្រួលពីខ្យល់ពេលព្រឹកដែលបក់ប៉ះកាយរបស់ខ្ញុំ។ ភ្នែករបស់ខ្ញុំសម្លឹងគ្រប់យ៉ាងដែលខ្ញុំអាចឃើញនៅលើទីខ្ពស់មួយនេះ ខ្ញុំឃើញរុក្ខជាតិ ផ្កា ខ្ញុំឃើញមនុស្ស ឃើញវត្ថុដែលផែនដីដ៏ធំនេះបង្កើតមក។ ខ្ញុំសម្លឹងចុះក្រោមមើលខ្លួនឯង ខ្ញុំប្រាប់ខ្លួនឯងថា ខ្ញុំរស់បាន៣៤ឆ្នាំហើយ។

ពេលវេលាដើរទៅមុខដូចជាយឺតណាស់ យឺតបំផុតពេលដែលរំពឹងឱ្យអ្វីមួយកើតឡើងឆាប់ៗ តែបើបានដើរហួសមកឆ្ងាយហើយវិញនោះ វាដូចជាលឿនណាស់ លឿនហួសដែលមិនអាចត្រឡប់ក្រោយវិញបាន។

ជីវិតកុមារភាពរបស់ខ្ញុំបានស្លាប់បាត់ហើយ... តែអនុស្សាវរីយ៍ និងការចងចាំល្អៗដែលខ្ញុំធ្លាប់មាន មិនបានស្លាប់ទៅណាទេ។ អនុស្សាវរីយ៍ដែលខ្ញុំពេញចិត្តបំផុតនោះ គឺជីវិតដែលពោលពេញទៅដោយស្នាមញញឹម ក្ដីសង្ឃឹម

មានន័យបំផុត ដែលអាចបានរស់នៅក្នុងពិភពនៃក្តីស្រលាញ់។

ខ្ញុំមិនចាំទេថាស្ថានភាពគ្រួសាររបស់ខ្ញុំកាលនោះពិបាកឬល្អយ៉ាងណា ការគ្រប់គ្រងគ្រួសារមិនមែនជាបន្ទុករបស់ក្មេងអាយុប្រាំ ប្រាំមួយឆ្នាំទេមែនទេ? ច្បាស់ណាស់! ក្មេងប៉ុណ្ណឹងអាចធ្វើអីបានក្រៅពីចាំតែទទួលយកក្តីស្រលាញ់ និងការថ្នាក់ថ្នមនោះ? ខ្ញុំត្រឹមជាក្មេងដែលប៉ាម៉ាក់នៅតាមលួងបញ្ចុកបាយសោះហ្នឹង។ ព្រោះគ្រួសារយើងជាអ្នកលក់ដូរ ម៉ាក់តែងអង្គុយលក់ដូរនៅមុខផ្ទះ ព្រឹកថ្ងៃនោះខ្ញុំនៅចាំបាន ម៉ាក់អង្គុយលក់បណ្តើរ ម៉ាក់ចាក់អាវឬចាក់អ្វីមិនដឹងទេ ម៉ាក់ចាក់វាផង អង្គុយលក់ដូរផង ហើយនៅលួងបញ្ចុកបាយកូនទម្រើសខ្ញុំនេះទៀត។ រឿងដែលខ្ញុំចាំបានមួយទៀត ពេលបាយថ្ងៃត្រង់មួយនោះ អ៊ំប្រុសខាងម៉ាក់របស់ខ្ញុំគាត់បានមកពិសារបាយផ្ទះខ្ញុំ ឃើញប៉ាកំពុងតែបេះសាច់បញ្ចុកបាយខ្ញុំ គាត់បង្អាប់ ថា "ខ្ញុំនេះធំហើយនៅឱ្យប៉ាម៉ាក់បញ្ចុកបាយទៀត!" កាលនោះពាក្យបង្អាប់របស់អ៊ំប្រុសមិនបានធ្វើឱ្យខ្ញុំឈឺក្បាលនោះទេ ខ្ញុំគ្រាន់តែដឹងថាប៉ាឬម៉ាក់មិនបញ្ចុកបាយ ខ្ញុំក៏មិនព្រមញ៉ាំដោយខ្លួនឯងដែរ។ កូនចៅអ្នកមានជីវភាពគួរសមដែរ តែរៀងកាយស្គមកំព្រឹងមិន

បាច់និយាយទេ កាលនោះបើម៉ាក់ប៉ាមិនខំលួងបញ្ចុកបាយទេ មិនដឹងខ្ញុំសល់ជីវិតដល់ថ្ងៃនេះឬអត់? ហិហិ... ខ្ញុំនៅចាំទិដ្ឋភាពបាយថ្ងៃត្រង់នៅផ្ទះចាស់ចង្អៀតរបស់ខ្ញុំនោះ ផ្ទះចង្អៀតតែមិនមែនផ្ទះតូចទេ គ្រាន់តែវាមានឥវ៉ាន់ដែលម៉ាក់ប៉ាទិញយកមកទុកលក់នោះវាច្រើនពេក ដល់ធ្វើឱ្យផ្ទះចង្អៀតរកតែផ្លូវដើរមិនចង់បាន។ តែផ្ទះតូច ឬផ្ទះធំ សុទ្ធតែជាផ្ទះនៃសុភមង្គលឱ្យតែបានរស់នៅក្នុងក្ដីស្រលាញ់។

កាលនៅតូចៗ ខ្ញុំចង់បានប្អូនម្នាក់ខ្លាំងណាស់។ ខ្ញុំធ្លាប់សុំម៉ាក់ឱ្យមានប្អូនម្នាក់ ព្រោះខ្ញុំឃើញក្មេងៗក្បែរផ្ទះខ្ញុំគេមានប្អូន គេលេងចូលគ្នាណាស់ រីឯខ្ញុំដូចជាតែឯងយ៉ាងម៉េចយ៉ាងម៉ាមិនដឹងទេ។ ទាំងដែលខ្ញុំក៏មានបងៗដែរ ខ្ញុំមានបងប្រុស ខ្ញុំមានបងស្រី តែព្រោះតែគម្លាតអាយុពួកយើងឆ្ងាយគ្នាបន្តិច? ឬមកពីបងស្រីគាត់ចូលចិត្តតែដើរតាមបងប្រុសពេក? ហើយខ្ញុំត្រឹមតែជាព្រះនាងដែលប៉ាថ្នមមិនឱ្យចេញក្រៅផ្ទះ ខ្ញុំគ្មានអនុស្សាវរីយ៍ក្បាលខូចដូចបងៗខ្ញុំទេ ហិហិ...។ ឧបករណ៍កំសាន្តរបស់ខ្ញុំគឺ ចានដំរឆ្នាំងដំរ ជាមួយនឹងកម្ទេចបន្លែដែលម៉ាក់ចិតចោលហ្នឹងហើយ អ៊ូ! ក៏មានឆ្នាំងដី អំបែងចាក់នំគ្រក់ដីដែរ។ មិនដឹងថាមាននរណាខ្លះសំណាងបានលេងល្បែងនេះជាមួយម៉ាក់ទេ? កុមារភាព

របស់ខ្ញុំ ជិតដាមជាមួយម៉ាក់ច្រើនដែរ។ ខ្ញុំមានម៉ាក់កំដរលេងដាំបាយ ចាក់នំគ្រក់ជាមួយ ព្រោះកាលនោះខ្ញុំមិនចេះរាប់អានមិត្តភ័ក្តទេ បើទោះមានក្មេងៗជិតខាងផ្ទះអាយុស្របាលគ្នាក៏ខ្ញុំមិនមានអារម្មណ៍ស្និទ្ធស្នាល ឬចង់ចេញទៅលេងនៅក្រៅជាមួយពួកគេដែរ។ កូនក្មេងតូចទម្រើសដូចខ្ញុំនេះ ចេះត្រឹមក្រោកពីព្រឹកសំកុកចាំប៉ានាំទៅញ៉ាំអាហារពេលព្រឹក មកវិញទារតាមម៉ាក់ទៅផ្សារ បើម៉ាក់មិនឱ្យទៅ ពេលម៉ាក់មកវិញតែងមានបង្អែម ឬមិនអីចឹងក៏ទិញល្បែងចានផ្តាំងមកផ្ញើខ្ញុំដែរ។ រាល់ថ្ងៃពេលរសៀល ខ្ញុំនេះតែងទៅតាមប៉ារហូត ទៅណា? ទៅញ៉ាំអាហារពេលរសៀលហ្នឹងហើយ។ ធ្លាប់ចាំ! មានម្តងអ្នកណាមិនដឹងទេសួរប៉ាថាខ្ញុំជាកូនអ្នកណា? ប៉ាថាជាក្មួយ! កាលនោះខ្ញុំខឹងប៉ាណាស់ មិនដឹងថាហេតុអីក៏ចេះខឹង មកដល់ផ្ទះភ្លាមទូលពិតម៉ាក់ភ្លាម កាលនោះខ្ញុំមិនទាន់ស្គាល់ក្រដាសលុយទេ តែកុំឱ្យឃើញប៉ាដកលុយក្រដាសពណ៌អីឱ្យអ្នកលក់ឱ្យសោះ មកវិញត្រូវតែប្រាប់ម៉ាក់ហើយ។ ប៉ានាំដើរតាមរហូត តែកូនស្រីមិនចេះនៅខាងប៉ាយ៉ាងម៉េច ហិហិ... ជាគិញរបស់ម៉ាក់សោះ។

ពេលមួយដែលទេវតាប្រទានផ្កាយ ខ្ញុំក៏មានប្អូនប្រុសម្នាក់ដូចចិត្ត ខ្ញុំគួរតែមានអ្នកកំដរលេងហើយមែនទេ?

មិនដឹងទេ! ខ្ញុំស្រាប់តែចេះច្រណែន ព្រោះអ្វីដែលខ្ញុំមានត្រូវតែចែករំលែកឱ្យគាត់។ ខឹងដល់ហើយ ពេលខ្លះគិតថាម៉ាក់ប៉ាស្រលាញ់ប្អូនជាងខ្ញុំ តែម៉ាក់ខ្ញុំប្រដៅឱ្យបងប្អូនត្រូវចេះស្រលាញ់គ្នានោះអី? ខ្ញុំក៏មិនដែលភ្លេចស្រលាញ់ប្អូនខ្ញុំ បើទោះជាអាល្អិតនេះកើតមកដើម្បីតែដណ្ដើមនំ និងរបស់លេងពីខ្ញុំក៏ដោយ។ ខ្ញុំចាំបានកាលនោះប្អូនតូចរបស់ខ្ញុំយំទឹកភ្នែករហាម ដណ្ដើមទឹកកកដែលខ្ញុំកំពុងញ៉ាំ ម៉ាក់មិនចង់ឱ្យប្អូនខ្ញុំញ៉ាំទឹកកកទេ ព្រោះតែខ្លាចឈឺ តែខ្ញុំនេះតាំងតួចេះអាណិតប្អូនណាស់ ខ្ញុំខាំបំបែកទឹកកកខ្ទាក់ចេញពីមាត់ទៅបញ្ចុកគាត់ ហិហិ ទើបតែដុះធ្មេញមុខពីរប៉ុណ្ណឹង គាត់មិនខ្វល់ថាទឹកកកនោះដែលមាត់បងស្រីគាត់ទេ ឱ្យតែបានញ៉ាំគឺគាត់ស្ងាត់យំហើយ តែថាទៅ កាលនោះ បើទោះដែលមាត់ក៏ដោយចុះ ក៏ខ្ញុំមិនចង់ចែកឱ្យដែរ បើមិនស្រលាញ់ប្អូនតិចថាឱ្យនោះ! ដឹងអត់ថាក្មេងសម័យខ្ញុំចូលចិត្តបៀមទឹកកកណាស់ ហិហិ..

ខ្ញុំនៅចាំអនុស្សាវរីយ៍មួយទៀតពីបងស្រីរបស់ខ្ញុំ! ជាកូនទម្រើស ខ្ញុំមិនចេះទ្រាំក្ដៅយ៉ាងម៉េចទេ ស្អិតខ្លួនបន្តិចក៏មិនព្រមគេងចាប់ផ្ដើមបង្រះពព្រូសរអ៊ូ ហើយមួយទៀតគឺម៉ូកម្ញក់មាឃីមាឃារខ្លាចសម្លេងភ្លៀងខ្លាំង ខ្លាចផ្លេកបន្ទោរ។

គិតទេថាបានគេងឱបម៉ាក់? គិតទៅ! ថាបើយំម៉ាក់ចេញមកលួងនោះ! ដឹងក្តីមកចាំតែមួយម៉ាត់យ៉ាងខ្លីថា "ខ្លាចម៉ាក់ស្តីឱ្យ" ។ ម៉ាក់ឱបតែអាពៅហ្នឹងឯង ខ្ញុំនៅក្នុងមុងជាមួយបងស្រីកម្សត់របស់ខ្ញុំ គាត់បក់ឱ្យទាល់តែខ្ញុំគេងលក់បើពេលដែលខ្ញុំក្តៅ ហើយគាត់ដណ្តប់ភួយនិងឱបពេលដែលខ្ញុំរងារពិសេសពេលភ្លៀងរន្ទះខ្លាំងៗ នោះហើយគឺអនុស្សាវរីយ៍ជិតដាម ដែលខ្ញុំមិនអាចភ្លេចគុណបងស្រីជាទីស្រលាញ់របស់ខ្ញុំបាន។ បងស្រីនិងខ្ញុំ មិនត្រឹមតែជាបងប្អូន ពួកយើងដូចជាមិត្តជិតស្និទ្ធ។ បងប្អូនខ្ញុំមិនដូចបងប្អូនមួយចំនួនផ្សេងនោះទេ ពួកយើងមិនចេះមើលបំណាំគ្នា ឈ្លោះគ្នានោះទេ ពួកយើងត្រូវគ្នាណាស់ ត្រូវគ្នារឿងខូចលាក់បាំងម៉ាក់ប៉ាហ្នឹងគឺលេខមួយហើយ។ មុនពេលគេងជាពេលដែលបងស្រី និងខ្ញុំជជែកគ្នាពីរឿងមិត្តភក្តិរៀងខ្លួន រឿងដែលកើតឡើងនៅសាលា និងរឿងម៉ាក់ប៉ា។ បងស្រីរបស់ខ្ញុំតែងទូន្មានឱ្យខ្ញុំចេះអាណិតម៉ាក់ប៉ា ប្រាប់ថាពួកគាត់ហត់ណាស់ កាលនោះបងស្រីទើបតែអាយុជាង១០ឆ្នាំទេ មិនដឹងថាគាត់ចេះគិតអីដែរហិហិ..។ បងស្រីរបស់ខ្ញុំមិនចូលចិត្តទៅរៀនទេ វ័យ១៤-១៥ឆ្នាំគាត់សម្រេចចិត្តឈប់ទៅសាលា និងចាប់យកជំនាញវិជ្ជាជីវៈមួយ។ វ័យ១៦ឆ្នាំ បងស្រីហ៊ានចេញទៅធ្វើការរកចំណូលដោយខ្លួនឯង។ ប្រាក់ខែដំបូងរបស់បងស្រីគឺយក

មកទិញកូនក្រមុំជ័រឱ្យខ្ញុំហ្នឹងហើយ អាវថ្លៃទី១ដែលខ្ញុំមានក៏បានពីបងស្រីដែរ។ បងស្រីរបស់ខ្ញុំលះបង់មិនតិចដើម្បីតែទម្រើសប្អូនស្រីក្បាលខូចខ្ញុំនេះឯង។

ចំណែកបងប្រុសធំរបស់ខ្ញុំវិញ ការចងចាំផ្អែមល្ហែមមួយនោះគឺនៅក្នុងវ័យ១២-១៣ឆ្នាំរបស់ខ្ញុំ។ ពេលដែលបងប្អូននៅឆ្ងាយគ្នា ទើបខ្ញុំដឹងថាការស្រលាញ់ចំពោះគ្នាពិតជាមានមែន។ កាលនោះបងប្រុសធំប្រឡងជាប់បាក់ឌុប គាត់ផ្លាស់មករៀនបន្តនៅភ្នំពេញ ខ្ញុំនៅឯខេត្តឯនេះចេះនឹកបងប្រុសខ្លួនឯង ចេះចង់ស្តាប់ម៉ាក់និយាយពីបង។ នឹកដល់រឿងរំភើបចិត្តដែលបងប្រុសតែងធ្វើឱ្យកាលនោះ គឺអត់មានអីពីការទម្រើសខ្ញុំឱ្យខូចនោះទេ ខ្ញុំរស់ដោយការទម្រើសតាំងពីតូច ខ្ញុំតែងទទួលបានរបស់ដែលខ្ញុំចង់បាន។ កាលនោះខ្ញុំចម្រើនដឹងក្តីបានបន្តិចហើយ ក្មេងមិនសូវខូចដូចខ្ញុំ មិនដែលនៅឆ្ងាយពីប៊ិកនិងសៀវភៅទេ តែចរិតមួយរបស់ខ្ញុំគឺពេញចិត្តតែអ្វីដែលប្លែកពីគេ ខ្ញុំចូលចិត្តប្រើប៊ិកដែលមានម៉ូតប្លែកៗ ស្អាតៗ ប៊ិកពណ៌ចម្រុះ។ ប៊ិកដែលខ្ញុំស្រលាញ់ថ្លៃណាស់ តែបងប្រុសខ្ញុំមិនសាញក្នុងការទិញផ្ញើឱ្យខ្ញុំប្រើទេ លក្ខខ័ណ្ឌងាយៗដើម្បីបានប៊ិកទាំងនោះ គ្រាន់តែសរសេរសំបុត្រទៅគាត់ជាភាសាអង់គ្លេស ហិហិ.. មិនពិបាកអីទេ

សរសេរតែពីរបីបន្ទាត់ក៏អាចបានរបស់ជាទីស្រលាញ់ហើយហ្នឹង។ នៅចាំបានច្បាស់ថាខោអាវម៉ាកឃីហោថ្លៃទីមួយ នៅហាងធំជាងគេនៅភ្នំពេញកាលជំនាន់នោះក៏បានពីបងប្រុសរបស់ខ្ញុំដែរ ទិញឱ្យចេះតែស្លៀកទៅ មិនទាន់ស្គាល់brandអីផង ហិហិ តែគាត់ត្រូវមាត់ម៉ាក់ប៉ាមីងមាសម្បើមណាស់។

វ័យ១៣-១៤ឆ្នាំជាវ័យដែលខ្ញុំមានរឿងល្អៗគួរឱ្យចងចាំច្រើនជាងគេ បើរាប់មកដល់ថ្ងៃនេះ។ ខ្ញុំធ្លាប់លួចឆ្លើយសំណួរមួយនោះថា បើសិនជាអាចបង្វិលពេលវេលាបាន តើអតីតកាលមួយណាដែលខ្ញុំចង់ត្រឡប់ទៅវិញ? គឺឆ្នាំនេះហើយ! ឆ្នាំ១៩៩៨ ដល់ ឆ្នាំ១៩៩៩ ខ្ញុំពេញចិត្តនឹងត្រឡប់ទៅវិញណាស់ បើក្តីសុខមួយនោះមិនផ្លាស់ប្តូរភាពលំបាករបស់ម៉ាក់ប៉ាខ្ញុំ។ អនុស្សាវរីយ៍នៅសាលារៀន! ខ្ញុំចាប់ផ្តើមចេះចូលរួមរីករាយនឹងកម្មវិធីផ្សេងៗជាមួយមិត្តភ័ក្ត លេងប៉ាតម្សៅ និងប្តូរកាដូថ្ងៃបុណ្យChristmas លេងល្បែងប្រពៃណីខ្មែរមុនពិធីបុណ្យចូលឆ្នាំខ្មែរ រៀនប្រកួតធ្វើមេរៀនឱ្យហើយមុនមិត្តភក្តិ ឆ្លតក្នុងការអាន ចូលចិត្តទិញនិងអានសៀវភៅ តែខ្ញុំមិនមែនជាសិស្សពូកែទេ ហិហិ..។ កាលនោះខ្ញុំមានមិត្តភក្តិល្អៗច្រើនណាស់ មានទាំងក្រុម តែខ្ញុំមានមិត្ត

ដែលស្រលាញ់ខ្លាំងពីរនាក់ សោម ម៉ាណែត និងហេង ស៊ីម៉ាឡែន ពួកយើងនៅតែមានទំនាក់ទំនងជាមួយគ្នាដល់ថ្ងៃនេះ។ ចាំថាកាលនោះខ្ញុំជាប់ឈ្មោះជាស្រីធ្លាស់ទៀតផង ហាសហា.. តែក៏នៅមានឈ្មោះជាមិត្តល្អ ជាសិស្សមិនខូច ហិហិ.. ហើយក៏ជាកូនល្អដែរ។

កាលពីនៅក្មេងៗ ខ្ញុំមិនចេះដើរលេងទៅណាឆ្ងាយនោះទេ សេចក្ដីសុខរបស់ខ្ញុំឱ្យតែបានទៅលេងផ្ទះមិត្តភក្តិ ជាពិសេសផ្ទះរបស់ម៉ាណែត ទៅផ្សារទិញបូរដណ្ដៀប ទៅបណ្ណាគារទិញសៀវភៅប៊ិក និងទៅបណ្ណាល័យបារាំងអានសៀវភៅនិទានភាសាបារាំងតែប៉ុណ្ណឹង កុំគិតថាខ្ញុំចេះបារាំងអី! គ្រាន់តែសាលាមានកម្មវិធីបង្រៀនភាសាបារាំង ខ្ញុំក៏ចេះបែប កខគ ដែរទៅ។

ជំទង់វ័យម៉ាក់បង្រៀនឱ្យខ្ញុំចេះធ្វើម្ហូបបានពីរបីមុខដែរ ខ្ញុំចាំបានពេលម៉ាក់ទៅភ្នំពេញមើលថែបងប្រុសនិងបងស្រី ខ្ញុំនៅផ្ទះជាមួយប៉ា និងប្អូនប្រុសពៅ។ ប៉ារបស់ខ្ញុំមួយថ្ងៃៗរវល់តែសរសេរបញ្ជីរនៅលើតុធ្វើការរបស់គាត់ មិនមានពេលឯណារៀបចំបាយទឹកឱ្យពួកយើងទេ គឺខ្ញុំនេះហើយជាអ្នកធ្វើការទាំងនេះពេលត្រឡប់មកពីសាលារៀនវិញ។ ខ្ញុំធ្វើម្ហូបម្ដងៗចេះតែសួរប៉ាពិសារកើតទេ? ប៉ាពិសារបានរហូត

ប៉ាសរសើរថាកូនស្រីគាត់ធ្វើម្ហូបបានញ៉ាំហើយ។ តែដឹងទេ? ភាគច្រើនគឺប៉ាប្រើឱ្យទៅកុម្ម៉ង់ម្ហូបពីហាងយកមកញ៉ាំសោះហ្នឹង ហិហិ...ស្រលាញ់ត្រង់ប៉ាលើកទឹកចិត្តកូនស្រីមករហូត។ ជំទង់វ័យរបស់ខ្ញុំ ឱ្យខ្ញុំស្និទ្ធស្នាលជាមួយប៉ាច្រើនជាងម៉ាក់ ប្រហែលមកពីកាលនោះម៉ាក់រវល់ជ្រៀកខ្លួនមកភ្នំពេញថែបងប្រុសបងស្រីខ្ញុំផង អ៊ីចឹងទុកឱ្យខ្ញុំមានឱកាសលួងប៉ាសុំនេះ សុំនោះមិនចេះចប់។ ព្រោះបើចង់បានអ្វីមួយកុំសុំអីម៉ាក់! មិនដែលបានទេ។ បើសុំប៉ាវិញ កុំថាឡើយត្រឹមសៀវភៅប៊ិកតូចតាច សុំដល់គ្រឿងអលង្ការក៏ប៉ាមិនដែលឱ្យចាំដែរ សុំថ្ងៃណាគឺបានថ្ងៃនោះ។ មានម្តងខ្ញុំសុំប៉ាទិញកាបូបទៅរៀនថ្មី សុំទម្រាំបានយូរដែរ ព្រោះទើបតែសុំទិញម្តងរួចហើយ ដល់ប៉ាព្រមឱ្យលុយទៅទិញ ខ្ញុំអរណាស់រត់ទៅផ្សារតែឯងទៅទិញកាបូបថ្មី កាបូបតូចៗស្ពាយក្រោយម៉ូតថ្មីទើបតែចេញ តែម៉ូតដែលខ្ញុំស្រលាញ់នោះវាថ្លៃណាស់ សុំលុយប៉ាមកមិនគ្រប់ ខ្ញុំបង្ខំចិត្តទិញអាមួយដែលថោកជាងហ្នឹងបន្តិចព្រោះគិតថាបើកាន់លុយមកផ្ទះវិញខ្ញុំប្រហែលមិនបានកាបូបថ្មីប្រើទេ។ មកដល់ផ្ទះមានរឿងអីកើតឡើង? ប៉ាសួរថាស្រលាញ់ទេ? ខ្ញុំឆ្លើយយកគួរទៀត! អាស្រលាញ់នោះវាថ្លៃណាស់ប៉ា អ៊ីចឹងក៏យកអានេះទៅ!។ គិតទេថាប៉ាសរសើរ? ប៉ាស្តីឱ្យបាត់! ប៉ាថាម៉េចមិនទិញអារបស់

ស្រលាញ់? បើខ្វះលុយម៉េចមិនមកយកលុយថែម? ខ្ញុំគាំង យោបល់ មិនហ៊ានតបប៉ាទៀតទេ ព្រោះដឹងថាប៉ាខឹងហើយ ខ្ញុំបានត្រឹមតែឱនមុខចុះ ហើយលបៗដើរចេញ។ ការ ចងចាំមួយដ៏កក់ក្ដៅ អ្នកលក់នាឡិកានៅហាងនោះប្រាប់ ប៉ាថា នាឡិកាម៉ូតនេះគាត់យកមកតែ២គ្រឿងទេ ព្រោះ វាថ្លៃណាស់ បន្ទាប់មកប៉ាទិញយកទាំងពីរគ្រឿង។ នាឡិកា ម៉ាកអីមិនចាំទេ! ដឹងតែម៉ូតស្អាតណាស់ខ្សែពណ៌ទឹកមាស មុខតូចប្រទ្បឹង មុខមួយពណ៌ទឹកមាស និងមួយទៀតពណ៌ ខ្មៅ សំណាងខ្ញុំបានរើសមុន ខ្ញុំយកមុខពណ៌ទឹកមាសហ្នឹង ហើយ។ នាឡិកាថ្មីជាទីស្រលាញ់ កុំថាដល់មិត្តភ័ក្ក សូម្បី តែលោកគ្រូអ្នកគ្រូបង្រៀនខ្ញុំក៏សរសើរពេញចិត្តនិងវាដែរ ហើយល្អអីយ៉ាងនេះ! ខ្ញុំពាក់មិនបានមួយអាទិត្យផង មិន ដឹងវាជ្រុះទៅណា? អ្នកណាក៏គិតថាប៉ានឹងវាយខ្ញុំដែរ តែសុំ ទោសទៅចុះ! ប៉ាគ្រាន់តែសួរថាវាជ្រុះមែន? ចាំប៉ា! វាជ្រុះ បាត់ហើយ។ មិនចាំបានទេថាកាលនោះខ្ញុំយំឬអត់ ប្រហែល អត់ទេ តែខូចចិត្ត! ខូចចិត្តមិនបានមួយអាទិត្យទេ ប៉ាទិញ នាឡិកាម៉ូតកងដៃថ្មីមួយទៀតឱ្យខ្ញុំបាត់ទៅហើយ មួយនេះក៏ ស្អាតដែរពណ៌ស ស្រលាញ់ណាស់ ហិហិ..។ អារម្មណ៍ដែល ត្រូវបានទម្រើស ដឹងទេវាមានក្ដីសុខណាស់! នឹកឃើញ ពេលណាមានក្ដីសុខពេលនោះ។

វ័យ១៥-១៦ឆ្នាំ ខ្ញុំផ្ដើមប្រើជីវិតវក់វង្វេងជាមួយមិត្តភក្ដិ។ កាលនោះគ្រួសាររបស់ខ្ញុំផ្លាស់មកនៅភ្នំពេញទាំងអស់គ្នាបានមួយឆ្នាំហើយ។ ខ្ញុំជាអ្នកចុងក្រោយដែលមកនៅភ្នំពេញក្រោយគេ ព្រោះប៉ាម៉ាក់ចាំឱ្យខ្ញុំប្រឡងឌីប្លូមរួចសិន។ ក្មេងស្រែៗមកពីខេត្តពេលទៅរៀន ដូចតែឯងៗម៉េចមិនដឹងទេ តែសំណាងខ្ញុំមិនសូវចេះនៅតែឯង ចូលរៀនមិនបានប៉ុន្មានខ្ញុំក៏មានមិត្តភក្ដិល្អហើយ។ នាងតូចម្នាក់នោះប្រហែលជាស្រីស្អាតប្រចាំថ្នាក់ផងក៏មិនដឹង រទ្បិករទ្បក់ណាស់ ហាសហា.. តែនាងរួសរាយហើយចិត្តល្អ ឮថាជាកូនគ្រូទៀតផង។ មិត្តថ្មីទីមួយដែលខ្ញុំរើសបាននោះឈ្មោះប៉ុល ប៉ូឡែត។ ប៉ូឡែតតែងមកទទួលខ្ញុំពីផ្ទះទៅសាលា គឺមួយហ្នឹងហើយ ដែលនាំខ្ញុំឱ្យស្គាល់មិត្តភក្ដិបន្តបន្ទាប់ ខ្ញុំដើររាប់មិត្តភក្ដិថ្មីរហូតដល់ទុកគាត់ចោល ហិហិហិ..។ មកពីកាលនោះគាត់ខូចដែរ តែដឹងទេ? ប៉ូឡែតនិងខ្ញុំនៅតែជាមិត្តនឹងគ្នាដល់បច្ចុប្បន្ន។ វ័យ១៦ឆ្នាំ វាគួរតែជាវ័យដែលក្មេងៗចាប់ផ្ដើមធំ? ចង់ដឹង ចង់យល់? ខ្ញុំពេលនោះ គឺចូលចិត្តស្វែងយល់ ចង់ដឹងចង់ឮ ពីរឿងហេតុផ្សេងៗ និងអារម្មណ៍ផ្សេងៗ ដែលកើតមានលើផែនដីនេះ ពិសេសគឺរឿងមនោសញ្ចេតនា ស្អីទៅជាក្ដីស្រលាញ់? ស្អីទៅជាការឈឺចាប់? ស្រលាញ់គេតែម្ខាងនោះយ៉ាងណា?។ បទចម្រៀង

ដែលខ្ញុំចូលចិត្តស្តាប់សុទ្ធសឹងជាបទមនោសញ្ចេតនា ការខូចចិត្ត។ ព្រោះតែចង់ស្គាល់ពីអារម្មណ៍មនោសញ្ចេតនាឱ្យបានច្រើន ខ្ញុំរីករាយជាទីប្រឹក្សារបស់មិត្តភក្តិមិនរើសមុខ មិនថាមិត្តភក្តិស្រី ឬប្រុសទេ ជំនាញរបស់ខ្ញុំគឺស្តាប់រឿង drama របស់មិត្តភ័ក្ត ស្តាប់ហើយគិត គិតហើយវិភាគ ហិហិ.. អស្ចារ្យណាស់ដឹងទេ? រឿងស្នេហារបស់មិត្តភ័ក្ត ខ្ញុំដឹងសឹងតែទាំងអស់! អ្នកណាលួចស្រលាញ់អ្នកណា អ្នកណាក្បាលខូចបោកចិត្តអ្នកណា ហាសហា..។ ល្បែងកំសាន្តរបស់ខ្ញុំមួយកាលនោះគឺសរសេរកំណាព្យ ឬបទចម្រៀងស្នេហារបស់មិត្តភ័ក្ត មិនអីចឹងក៏សរសេរបង្អាប់រូបឆោមមិត្តភក្តិប្រុសៗហ្នឹងហើយ។ សាហាវបំផុតនោះគឺ សរសេរហើយយកទៅហ្វូតូកូពីចែកមិត្តភក្តិពេញតែថ្នាក់រៀន ហាសហា.. ដឹងទេនាមប៉ាការបស់ខ្ញុំគឺអ្វី? ប្រាប់ទៅចុះ! **ផ្កាយតូច** ។ ជានាមប៉ាកាដែលខ្ញុំស្រលាញ់ ហើយបានប្រើនាមនេះដាក់ទៅក្នុងស្នាដៃប្រលោមលោកទីមួយដែលខ្ញុំសរសេរ។

ក្រៅពីរឿងកំប្លែងទាំងនោះ ខ្ញុំនៅមានរឿងមោទនៈភាពមួយ ដែលធ្វើឱ្យខ្ញុំពេញចិត្តនឹងខ្លួនឯងបំផុត ចង់ដឹងទេ? មួយនោះគឺ ការកំណត់គោលដៅឱ្យខ្លួនឯង ខ្ញុំមិនដឹងថាខ្ញុំចេះពីណាមកទេ តែខ្ញុំក៏ធ្វើបាន។ ខ្ញុំប្រាប់ខ្លួនឯង! បើ

មិនទាន់រៀនចប់បាក់ឌុបទេ ហាមទៅមើលកុន! ហាមដើរលេងផ្តេសផ្តាស! ហាមមានសង្សារ! ហើយដឹងទេ? គ្រាន់តែប្រលងបាក់ឌុបហើយភ្លាម មិនចាំបាច់ចាំដល់ប្រកាសលទ្ធផលរួចសិនអីទេ ខ្ញុំប្រែកាយក្លាយជាចាបក្រៅទ្រុងទៅហើយ។ ខ្ញុំចូលចិត្តមើលកុន ចូលចិត្តទៅញ៉ាំអីនៅត្រើយម្ខាងភ្នំពេញ ដែលគេហៅថាបាក់ខែងនោះអី! ឆ្នាំ២០០២ហើយ កាលនោះមានហាងតែគុជ និងហាងការ៉េមខ្លះហើយ ពេលទំនេររបស់ខ្ញុំភាគច្រើននៅតែទីនោះឯង មានពេលតិចណាស់ដែលខ្ញុំទៅបណ្ណាល័យ តែខ្ញុំមិនទាន់បោះបង់ចោលការអាន និងការសរសេរដែរ ខ្ញុំនៅចូលចិត្តទិញសៀវភៅយកមកអាននៅផ្ទះ ហើយសរសេរនៅពេលដែលខ្ញុំមានអារម្មណ៍ស្ងប់ស្ងាត់ ស្ងាត់រហូតដល់មិនដឹងថាត្រូវសរសេរពីអ្វី ក៏ត្រូវតែបង្កើតរឿងមួយដើម្បីសរសេរកែរអផ្សុកទៅ ខ្ញុំធ្វើបែបនេះស្ទើតែរាល់ថ្ងៃ រាល់ពេលល្ងាចនិងពេលយប់ ព្រោះពេលព្រឹកនិងពេលថ្ងៃរសៀលខ្ញុំបាត់ស្រមោលពីផ្ទះហើយ ហិហិ..។ ខ្ញុំមានមិត្តភក្តិល្អម្នាក់ គាត់ចូលចិត្តហៅខ្ញុំចេញក្រៅជាមួយគ្នាណាស់ ពួកយើងជាមិត្តយល់ចិត្ត តែងកំដរគ្នាទៅវិញទៅមក អាចនិយាយរឿងក្នុងចិត្តប្រាប់គ្នាដោយមិនរអារ មិនបារម្ភថា អ្នកណានឹងយករឿងនោះទៅនិយាយបន្តឡើយ។ យើងស្និទ្ធស្នាលគ្នាលក្ខណៈពេលជួប

គ្នាគឺប្តូរទូរស័ព្ទគ្នាឆែកមើលសារលេង ហិហិ.. ខ្ញុំអានសារដែលគេផ្ញើឱ្យគាត់ គាត់អានសារដែលគេផ្ញើឱ្យខ្ញុំ ណ្ហើយ! មួយម៉ាត់យ៉ាងខ្លី! ខ្ញុំស្រលាញ់មិត្តភាពដែលមានជាមួយគាត់ណាស់។ រឿងល្អបំផុតមួយដែលខ្ញុំទទួលបានពីមិត្តម្នាក់នោះ គឺតាំងពីរាប់អានគ្នាមកដល់ថ្ងៃនេះ១៩ឆ្នាំហើយ ពួកយើងមិនដែលឈ្លោះគ្នាសូម្បីតែម្តង។ មានអន់ចិត្តគ្នាតែម្តងគត់ កាលពីយើងនៅរៀន ព្រោះតែគាត់ចេញទៅសាលាមុនខ្ញុំទៅដល់ផ្ទះគាត់ដើម្បីចេញទៅសាលាព្រមគ្នាតាមទម្លាប់ ហិហិ... រឿងប៉ុណ្ណឹង! ខ្ញុំអន់ចិត្តនឹងគាត់ ខ្ញុំមិនមើលមុខ មិនស្តីឆ្លើយ មិនទៅណាជាមួយគាត់អស់មួយព្រឹកគត់ ទម្រាំតែបើកមាត់ព្រមនិយាយជាមួយគាត់វិញ។ គាត់ក៏មិនបានងរង៉ក់តបខ្ញុំវិញដែរ ល្អត្រង់គាត់ចាំឱ្យខ្ញុំឈប់អន់ចិត្ត ត្រជាក់ចិត្ត ទើបគាត់ប្រាប់ហេតុផលដែលធ្វើឱ្យខ្ញុំអន់ចិត្តនោះ ហើយពួកយើងក៏ធម្មតានឹងគ្នាវិញ។ រកឯណាបានដូចមិត្តម្នាក់នេះទេ ខ្ញុំស្ញប់ស្ញែងចិត្តអំណត់របស់គាត់ និងស្រលាញ់ទឹកចិត្តល្អរបស់គាត់ចំពោះខ្ញុំ និយាយដោយស្មោះ! គាត់តែងតែឱ្យខ្ញុំទី១ ខ្ញុំកក់ក្តៅនឹងមិត្តភាពនេះណាស់។ ហើយគាត់នេះហើយ ដែលត្រូវបានខ្ញុំយកមកពីពណ៌នានៅក្នុងប្រធានបទតែងសេចក្តីមួយ កាលដែលគ្រូមុខវិជ្ជាភាសាអង់គ្លេសក្រៅម៉ោងរបស់ខ្ញុំ ដាក់ប្រធានបទឱ្យពិពណ៌នាអំពីមិត្តល្អ

ម្នាក់។ កាលនោះខ្ញុំមិនបាច់គិតយូរ! បើទោះជាខ្ញុំមានមិត្ត ជិតស្និទ្ធ ឬមិត្តល្អច្រើន តែគ្រាន់តែអានប្រធានបទនោះ ហើយខ្ញុំញញឹមនឹកដល់ឈ្មោះគាត់តែម្តង គួរតែប្រាប់ឈ្មោះ គាត់ទេ? ប្រាប់បាន! គាត់ឈ្មោះ សួន ស៊ីមុនី គាត់ជាចំនែក នៃអនុស្សាវរីយ៍ល្អមួយរបស់ខ្ញុំ។

វ័យ១៨ឆ្នាំ ខ្ញុំសម្រេចបានប្រលោមលោកពាក់កណ្តាលរឿង ហិហិ..។ រីឯអនុស្សាវរីយ៍ពិសេសមួយទៀតនោះ ក្នុងវ័យ១៨ឆ្នាំដដែលនេះ វាគឺជាមោទនៈភាពដែលខ្ញុំនឹងយកមករំឭកប្រាប់ទៅជំនាន់ក្រោយរបស់ខ្ញុំរហូតទៅ ខ្ញុំទទួលបានការងារធ្វើក្នុងអាយុ១៨ឆ្នាំ! ជាកញ្ញារដ្ឋបាលនៅក្នុងអង្គការក្រៅរដ្ឋាភិបាលមួយ។ ខ្ញុំមានសេចក្តីសុខនឹងពាក្យដែលគេហៅនោះណាស់ កញ្ញារដ្ឋបាល! ទើបតែអាយុ១៨ឆ្នាំសោះ ខ្ញុំអាចធ្វើជាកញ្ញារដ្ឋបាលហើយ? ចេះការងារអីខ្លះ? មិនចេះអីទេ! ធ្វើការនៅចាំបងៗរួមការងារជួយដឹកដៃតែរហូតហ្នឹង ខ្ញុំគ្រាន់តែសំណាងបានជួបមនុស្សល្អ ចេះអធ្យាស្រ័យ យល់ទុក្ខធុរៈតែប៉ុណ្ណឹង។ វាជាលើកទីមួយដែលជីវិតមួយនេះចាប់ផ្តើមស្គាល់សង្គមខាងក្រៅ ខ្ញុំផ្តើមមានឱកាសបានស្តាប់មិត្តរួមការងារជំណាលពីជីវិតគ្រួសារឯកជនរបស់ពួកគេ ជាស្ថានភាព និងជីវភាពផ្សេងៗគ្នា

ហើយវាថ្មីបំផុតដែលខ្ញុំពុំធ្លាប់ជួប ពុំធ្លាប់ឮសោះពីមុនមក។ ការងារនាំខ្ញុំឱ្យមកស្គាល់មនុស្សដែលមានជីវភាពខុសពីអ្វីដែលខ្ញុំគិត ខ្ញុំមិនធ្លាប់ស្រមៃដល់ថា មនុស្សអាចមានគម្លាតជីវភាព និងភាពរីករាយឆ្ងាយគ្នាដល់ម្លឹង។ ក្មេងដែលមណ្ឌលចិញ្ចឹមនោះវាយ៉ាងម៉េចទៅ? មិត្តរួមការងារខ្ញុំម្នាក់ជាក្មេងដែលមណ្ឌលចិញ្ចឹមតាំងពីតូច។ ខ្ញុំចាប់ផ្តើមចាប់អារម្មណ៍អង្គុយស្តាប់រឿងរបស់គាត់ ពេលមួយដែលគាត់មកសុំអំបិលមីដែលខ្ញុំមិនត្រូវការ យកទៅរោយបាយញាំុ? (កាលនោះខ្ញុំចូលចិត្តញាំុមីកញ្ចប់បែបឆៅ មិនស្រុសទឹកក្តៅហើយចោលគ្រឿងសម្រាប់ឆុងមី) ។ ខ្ញុំឆ្ងល់! ធ្វើអ៊ីចឹងបានដែរ? គេធ្វើបានតែខ្ញុំមិនដែលឮ។ ពេលនោះខ្ញុំក៏ភ្ញាក់ អ៎! ជីវិតលើផែនដីនេះមិនដូចគ្នាសោះ។

មុនអាយុ១៨ឆ្នាំ ខ្ញុំរស់នៅក្នុងសង្គមមិនខ្វះខាត មិត្តភក្តិរបស់ខ្ញុំមិនមានជីវភាពខុសពីគ្រួសារខ្ញុំឡើយ។ រាល់ប្រធានបទដែលយើងនិយាយឡើង មានតែរឿងដែលយើងទទួលបានមក ជារបស់នេះ ឬរបស់នោះ និងរឿងដែលឯរម៉ាក់ប៉ា បងប្អូន មិនដែលមានប្រធានបទកង្វះខាតផ្នែកជីវភាពគ្រួសារអីនោះឡើយ។ ខ្ញុំស្មានតែកើតមកត្រូវតែដូចគ្នា! តាមពិតខ្ញុំនិងមិត្តភក្តិ គ្រាន់តែនៅក្នុងក្រុមមនុស្សដែល

មានសំណាងប៉ុណ្ណោះ។ វាពិតជាប្លែកណាស់ក្រោយដឹងថា មនុស្សរស់នៅលើផែនដីតែមួយ តែមិនទទួលបានអ្វីដូចគ្នា ខ្ញុំចាប់ផ្តើមរៀនស្វែងយល់ពីជីវភាពផ្សេងៗ និងទុក្ខលំបាកផ្សេងៗ។

ខ្ញុំ! គឺបែបនេះហើយ! ចូលចិត្តចង់ដឹង ចង់ឮអ្វីដែលថ្មី និងប្លែក ចង់ស្គាល់ពីអារម្មណ៍ ចង់យល់ពីហេតុការណ៍។

អនុស្សាវរីយ៍កាលពីអាយុ២១ឆ្នាំគឺជារឿងកំប្លែងប្រចាំជីវិត។ ខ្ញុំនៅជាកូនក្មេងដែលល្ងង់មិនដឹងអីនៅឡើយទេ! ប្រៀបក្មេងសម័យនេះ គេមានសង្សារពីរបីនាក់ទៅហើយទេដឹង? ឯខ្ញុំវិញមិនយល់ថាក្តីស្រលាញ់បែបប្រុសស្រីនោះវាយ៉ាងម៉េចទេ? ថ្ងៃមួយនោះ! វាប្រហែលជាឆ្នាំដំបូងដែលខ្ញុំចាប់ផ្តើមចាប់អារម្មណ៍ថ្ងៃបុណ្យនៃក្តីស្រលាញ់នោះទេដឹង? មិនច្បាស់ទេ! តែចាំបានថា កាលនោះខ្ញុំល្ងង់ទទួលកាដូ និងបាច់ផ្កានៃក្តីស្រលាញ់ពីមនុស្សមិនចេះតិចនាក់ ^v^ ។ ខ្ញុំចាំបានថា បានទទួលបាច់ផ្កាពីបងស្រីម្នាក់ គាត់ឈ្មោះបងមុំ ឈ្មោះពិតរបស់គាត់ពិរោះណាស់គាត់ឈ្មោះ អ៊ុនពៅរ៉ូសាណា គាត់នៅតែជាបងស្រីខ្ញុំដល់សព្វថ្ងៃនេះ។ ក្រៅពីបាច់ផ្ការបស់បងមុំ ខ្ញុំនៅទទួលបានស្ករសូកូឡា បាច់ផ្កា និងកាដូផ្សេងៗពីបុរស៨នាក់ដែលខ្ញុំ

គ្រាន់តែចាត់ទុកពួកគេជាមិត្តតែប៉ុណ្ណោះ ហាសហា.. អ្នកនាងអើយ! ចេះធ្វើទៅរួច! នេះជារឿងកំប្លែងស្ងួតប្រចាំជីវិតខ្ញុំហើយ។ តែវាពិតមែន! សម្រាប់បុរសទាំង៨នាក់នោះ ឱ្យលើសពីមិត្តយ៉ាងម៉េចទៅបើខ្ញុំកាលនោះមិនទាន់ចេះស្រលាញ់ផង? ហាហាហា... អ្នកអានមិនជឿទេមែនទេ? មិនជឿក៏មិនអី ហាសហា.. ។ ដល់ថ្ងៃនេះខ្ញុំនៅតែមិនយល់ថាកាលនោះគិតអី គ្រាន់តែចាំថាកាលនោះជាថ្ងៃបុណ្យនៃក្ដីស្រលាញ់ បងមុំគ្រាន់តែដឹងថាខ្ញុំចូលចិត្តផ្កា គាត់បានឱ្យគេខ្ចប់ផ្កាយ៉ាងស្អាតជូនមកខ្ញុំ ហើយអ្នកផ្សេងទាំង៨នាក់នោះគិតអី? ខ្ញុំមិនដឹងទេ! គេឱ្យខ្ញុំក៏យក ខ្លាចគេអន់ចិត្ត? ហាសហា..។ តែពួកយើងក៏នៅតែជាមិត្តដដែល ហើយអ្នកខ្លះក្នុងចំណោមទាំង៨នាក់នោះនៅតែជាមិត្តរបស់ខ្ញុំដល់សព្វថ្ងៃនេះទៀតផង។ រឿងមួយនោះវាក្លាយជាការចងចាំមួយសម្រាប់ខ្ញុំ ទុកឱ្យខ្ញុំបានរំឭកខ្លួនឯងឱ្យបានសើចរាល់ថ្ងៃ១៤កុម្ភៈនោះអី!។ ឱ! អនុស្សាវរីយ៍ក្មេងល្ងង់! តែវាបានជិតជាមការចងចាំនៃក្ដីស្រលាញ់ ក្ដីពេញចិត្តដែលមិនគួរបំភ្លេចទេ។ ណ្ហើយ! គ្រាន់តែចាំថា ឆ្នាំនោះជាឆ្នាំដែលខ្ញុំបានទទួលកាដូក្ដីស្រលាញ់ច្រើនបំផុតទៅដឹង?

រស់បាន២៤ឆ្នាំ! ខ្ញុំចាប់ផ្តើមឈានជើងឡើងកាំជណ្តើរនៃក្តីសុបិន្ត វាជាសុបិន្តមួយដែលខ្ញុំមានកាលពីនៅអាយុ១៣-១៤ឆ្នាំ។ ខ្ញុំប៉ងធ្វើជាលេខា ទាំងដែលកាលនោះខ្ញុំមិនដឹងថាកិច្ចការរបស់លេខាគេធ្វើអីខ្លះផង ខ្ញុំធ្លាប់និយាយថាខ្ញុំ ចង់ធ្វើលេខារបស់ប្រធានក្រុមហ៊ុន។ តែវាហាក់ដូចជាសំណាងមួយដែលខ្ញុំស្រាប់តែឡើងមកដល់តំណែងមួយដែលធ្លាប់ប៉ងបែបនេះ។ Secretary to CEO មិនអន់ទេណា! ខ្ញុំខំធ្វើការប៉ុន្មានឆ្នាំ? បានជួបអ្វីខ្លះ? មិនមែនសុខៗក៏ហោះមកដល់ក្តីស្រមៃឯណា! តែយ៉ាងណា នេះជាតំណែងដែលខ្ញុំស្រលាញ់ជាងក្នុងចំណោមតំណែងការងារទាំងអស់ដែលខ្ញុំទទួលបាន។ តំណែងមួយនេះបានដាស់ខ្ញុំឱ្យភ្ញាក់ថា ខ្ញុំធំហើយ! ថាវាដល់ពេលហើយ ដែលខ្ញុំត្រូវបើកទ្វារនៃក្តីស្រមៃរបស់ខ្លួនឯងបន្តទៅទៀត។ បើទោះពេលនោះខ្ញុំកំពុងទទួលបានតំណែងមួយដែលខ្ញុំស្រលាញ់ខ្លាំង ក៏មិនមែនអនាគតរបស់ខ្ញុំត្រូវឈរនឹងថ្កល់នៅចំនុចមួយនោះហូតដែរ។ អាចចាត់ថាវាជាការត្រៀមឡើងជណ្តើរមួយកាំទៀតដើម្បីបានទៅដល់ទីខ្ពស់មួយ ដែលខ្ញុំចេះតែងើយសម្លឹងមើលរាល់ថ្ងៃទៅចុះ។

អាយុ៣០ឆ្នាំទៅហើយ ខ្ញុំទើបតែបានផ្លោះរបួចពីអណ្ដូងដែលខ្ញុំរស់នៅ។ ខ្ញុំទៅណា? ជាលើកទីមួយដែលខ្ញុំមានឱកាសបានមើលឃើញពិភលោកខាងក្រៅ ប្រទេសដទៃពិតជាប្លែកភ្នែកពីប្រទេសយើងពិតមែន។ អនុស្សាវរីយ៍មួយនេះតើឱ្យបកស្រាយបែបណា? ខ្ញុំបានឃើញរបស់មួយចំនួនដែលខ្ញុំធ្លាប់តែឃើញនៅក្នុងយល់សប្ដិ ឃើញអ្វីផ្សេងៗទៀតដែលខ្ញុំមិនធ្លាប់គិតដល់ ខ្ញុំបានស្ដាប់រឿងហេតុដែលកើតឡើងនៅកន្លែងខ្លះៗដែលខ្ញុំធ្លាប់តែដឹងតាមយល់សប្ដិខ្លួនឯង។ ពិសេសដល់ហើយហ្ន៎! រឿងក្នុងយល់សប្ដិក៏អាចក្លាយជារឿងពិតបានដែរ។ តាំងពីមានបទពិសោធន៍ចេញក្រៅអណ្ដូងម្ដងមក ការប្រកាន់ពាក្យថា “ដើរលេងស្រុកឯងឱ្យអស់សិន” ត្រូវបានលាក់ទុកលែងនិយាយហើយ ហិហិ.. ខ្ញុំបង្កើតពាក្យថ្មីសម្រាប់ខ្លួនឯង “មួយឆ្នាំ! ត្រូវនាំខ្លួនឯងទៅកន្លែងដែលមិនធ្លាប់ទៅយ៉ាងហោចឱ្យបានមួយកន្លែង” ។ ពីពេលនោះមក ខ្ញុំតែងរកឱកាសឱ្យខ្លួនឯងបានទៅកន្លែងប្លែកៗដែលខ្ញុំពុំធ្លាប់ទៅ មិនថាក្នុងស្រុក ឬក្រៅស្រុក។ ការប្រើជីវិតជាអ្នកស្រលាញ់ការទេសចរណ៍ មានក្ដីសុខណាស់! ជឿទៅ! នៅពេលដែលយើងស្រលាញ់ យើងនឹងតែងតែរកវិធីយកវាឱ្យបានហើយ។ មិនពិបាកទេគ្រាន់តែរកវិធីដើរលេង!

៣១ឆ្នាំហើយ! មានក្ដីស្រមៃមួយមិនទាន់សម្រេចបាន។ ខ្ញុំសាំចិត្តខ្លាំងមែនទែន! ចង់ចេញសៀវភៅមួយក្បាលគេធ្វើយ៉ាងម៉េចទៅ? រឿងដែលខ្ញុំខំសរសេរមករាប់ឆ្នាំហើយនោះយកជាការបានឬអត់? តើសរសេរប្រលោមលោកឱ្យត្រូវក្បួនខ្នាតត្រូវបេះអីខ្លះ? ខ្ញុំមិនស្គាល់អ្នកណាក្នុងវិស័យនេះទេ និយាយឱ្យអស់មិនមានជីវិតជាសិស្សនិស្សិតទៀតទេ មនុស្សដែលខ្ញុំស្គាល់និយាយតែការងារដែលមិនទាក់ទងនឹងចំណេះដឹងពីការសរសេរប្រលោមលោកសោះ!

ត្រូវអរគុណFacebook ខ្ញុំសំណាងទៅមាន friend ក្នុងfacebook ជាមួយអ្នកនិពន្ធល្បីពីពេលណា? សាកសួរគាត់បន្តិចទៅហ្ន៎ក្រែងលោគាត់អាចជួយបានខ្លះ? អ្នកនិពន្ធចិត្តល្អទេហ្ន៎? សុខៗទៅសួរគាត់អីចឹងគាត់ប្រាប់ឬអត់? សាកបានដឹង!

ក្រោយchatសួរនាំ បងប្រុសអ្នកនិពន្ធដែលមានទឹកចិត្តល្អម្នាក់នោះមក គាត់ហៅឱ្យខ្ញុំទៅចូលរួមក្រុមជាមួយគាត់ មានដែរហ្ន៎? គាត់ចិត្តល្អបង្រៀនជំនាន់ក្រោយមួយក្រុមពីរបៀបតែងនិពន្ធ ខ្ញុំសរសើទឹកចិត្តអ្នកនិពន្ធសុខ ចាន់ផល មែនៗ! ក្រោយចូលប្រជុំក្រុមជាមួយគាត់

បានតែម្ដងខ្ញុំក៏ចេះសរសេរប្រលោមលោកខ្លី ហិហិ តែគោលបំណងខ្ញុំគឺវិធីសាស្ត្រសរសេរប្រលោមលោកវែងទេតើ!

ទម្រាំតែខ្យល់វាសនាបក់ក្ដីសុបិនឱ្យក្លាយជាការពិត អាយុ៣២-៣៣ឆ្នាំបាត់ទៅហើយ! រឿងវានៅថ្មីៗ ការចងចាំក៏នៅសល់ច្រើន។ អនុស្សាវរីយ៍មួយនេះប្រហែលជារៀបរាប់បានច្រើនណាស់ហើយទេដឹង? គ្មានអភិនិហាឯណាមកជប់សាច់រឿងដែលខ្ញុំបានសរសេរនោះឱ្យក្លាយជាសៀវភៅតូចដែលគួរឱ្យស្រលាញ់បានមួយក្បាលសោះ!។ ទាល់តម្រិះ ខ្ញុំបោះបង់ចោលការអានសៀវភៅភាសាបរទេសហើយចាប់យកការអានសៀវភៅជាភាសាជាតិ ស្នាដៃអ្នកនិពន្ធខ្មែរយើងវិញម្ដងមើល។ តើប្រលោមលោករបស់គេនិងខ្ញុំមានអីប្លែកគ្នាទេ? ខ្ញុំដើរប្រមូលទិញប្រលោមលោកនិងសៀវភៅល្បីៗមិនតិចក្បាល សៀវភៅខ្លះក៏អានចប់ ខ្លះក៏មិនចប់នៅតែរកមិនឃើញអ្វីដែលខ្ញុំចង់រក។

រហូតថ្ងៃមួយ... បានជួបអ្នកណាគេ? មនុស្សមានចំណេះដឹងមិនអន់ តែសែនសាមញ្ញ! ស្មានតែជាអ្នកដឹកជញ្ជូនសៀវភៅធម្មតាទេតើ តាមពិតជាកវីនិពន្ធផង ជាអ្នកកែសម្រួលសៀវភៅល្បីៗមិនតិចចំណាងជើងផង។ ខ្ញុំសែនមានសំណាងដែលបានជួបគាត់ គាត់ជាពន្លឺប្រទីបជួយឱ្យ

ស្នាដៃជាទីស្រលាញ់មួយនោះរបស់ខ្ញុំចេញជារូបរាង យ៉ាងណាក្នុងនោះនៅមានរៀមច្បងជាទីគោរពម្នាក់ទៀតដែរ ខ្ញុំស្ញប់ស្ញែងដែលគាត់ខំយកពេលវេលារបស់គាត់ជួយកែតម្រូវរបៀបវារៈនៃការសរសេរ និងអក្ខរាវារុទ្ធ ដែលខ្ញុំមានចន្លោះ ឬខុសឆ្គង។ មិនលាក់ទេ អ្នកជាទីគោរពទាំងពីរនាក់នោះគឺ ប្អូនប្រុស ហ៊ួន ស៊ីឡូន និងបងប្រុសឡឹក ជំនោរ នេះហើយ។ ឃើញរូបរាងដ៏ស្រស់ស្អាតរបស់ប្រលោមលោកវិថីជីវិត ពេលណា ក៏នឹកដល់គុណអ្នកទាំងពីរភ្លាមនោះ។

ដំណើរជីវិតជាអ្នកនិពន្ធទាំងដែលមិនដឹងថាខ្លួនឯងមានលក្ខណៈគ្រប់គ្រាន់ជាអ្នកនិពន្ធ ឬក៏អត់ផងទេ មានសើច មានយំ យំមិនមែនព្រោះឈឺចាប់ យំព្រោះតែក្តីរំភើបរីករាយ។ អារម្មណ៍រំភើបពេលនោះមិនទាន់ចេញពីការចងចាំរបស់ខ្ញុំពេលនេះទេ អត្ថបទដែលធ្លាប់តែមិត្តភក្តិបង្អាប់ថា Drama ឬរៀបរាប់ឥតបានការ ក្លាយទៅជាអត្ថបទលើកទឹកចិត្ត នាំមនុស្សមួយក្រុមឱ្យមានកម្លាំងចិត្ត និងរីករាយដោយការបានអានអត្ថបទទាំងនោះរបស់ខ្ញុំ។ ឱ! អារម្មណ៍នោះអើយ! ពិសេសយ៉ាងនេះ! នេះឬអារម្មណ៍ពេលជួប

មនុស្សមានចិត្តដូចគ្នា? នឹកឃើញពេលណាក៏រំភើបនិងកាន់តែស្រលាញ់ fans របស់ខ្ញុំ។

ខ្ញុំនៅចាំប្អូនស្រីឈ្មោះ ទឹន សុលីដា ជាអ្នកshare អត្ថបទរបស់ខ្ញុំមុនគេបំផុត។ លើកទីមួយដែលខ្ញុំប្រើឈ្មោះជាអ្នកនិពន្ធ ខ្ញុំបានបង្ហោះអត្ថបទតំបូងមួយនោះ ប្អូនស្រីក៏ក្លាយជាfan ទីមួយដែលបាន shared ចេញ។ បើអត់មានអ្នក shareទីមួយធ្វើយ៉ាងណានឹងមានអ្នកshareបន្តបន្ទាប់មែនទេ? អរគុណលីដាដែលធ្វើជាអ្នកគាំទ្រទី១ របស់បង។

អ្នកណាទៀត? ទំព័រថ្មីដែលខ្ញុំមិនធ្លាប់មានបទពិសោធន៍អ្វីបន្តិចសោះ មិនដឹងថាអ្វីគួរឬមិនគួរទេ កាយវិការការនិយាយស្តីនីមួយៗ ខ្ញុំប្រើដោយការប្រុងប្រយ័ត្ន។ ថ្ងៃមួយនោះ មានអារម្មណ៍ចុកតិចៗ ប្រហែលជាការសរសេររបស់ខ្ញុំគួរឱ្យចាប់អារម្មណ៍ខ្លាំង មានpage មួយបានលួចយកអត្ថបទមួយរបស់ខ្ញុំទៅបង្ហោះដោយមិនទុក credit ឱ្យម្ចាស់ស្នាដៃ ខ្ញុំខ្លួនឯងពេលនោះមិនដឹងថាគួរធ្វើបែបណាល្អទេ។ នៅចាំបានអារម្មណ៍មួយនោះ ឈឺតិចតែរំភើបច្រើនព្រោះខ្ញុំទទួលបានភាពកក់ក្តៅពីអ្នកគាំទ្រមិនតិចនាក់ គាត់មិននៅស្ងៀមនៅពេលដែលអត្ថបទខ្ញុំត្រូវបានគេលួចយក

ទៅ។ នៅចាំមិនទាន់ភ្លេចប្អូនស្រីម្នាក់ដែលសកម្មបំផុតនោះទេ គាត់ចេញមុខការពារបងស្រីម្នាក់ដែលគាត់មិនធ្លាប់ជួបមុខសោះ ប្អូនស្រី មាស ដាលីន ដែលសព្វថ្ងៃគាត់កំពុងធ្វើការនៅប្រទេសកូរេងណោះ។ នឹកដល់ពេលវេលានោះណាស់! ពេលដែលយើងមិនដឹងថាគួរធ្វើយ៉ាងណា ក៏ស្រាប់តែមានមនុស្សមកស្ម័គ្រធ្វើជារណាំងឱ្យបែបនេះ។ អរគុណណាស់ប្អូនសម្លាញ់។

អារម្មណ៍ពិសេសមួយទៀតដែលពិបាកបំភ្លេច! មួយថ្ងៃក្រោយថ្ងៃគម្រប់ខួប៣៣ឆ្នាំនេះហើយ។ វាជាលើកទី១ដែលខ្ញុំទទួលយកក្ដីស្រលាញ់ពីមនុស្សដែលខ្ញុំមិនធ្លាប់ជួបសោះពីមុន។ មនុស្សបីនាក់បានលួចរៀបចំធ្វើពិធីខួបកំណើតឱ្យបងស្រីអ្នកនិពន្ធម្នាក់នេះបានរីករាយ និងភ្ញាក់ផ្អើល។ ខ្ញុំរំភើបនឹងក្ដីស្រលាញ់មួយនេះណាស់ ប្អូនស្រី រីកា ប្អូនស្រី ស៊ុយ ស្រីនិច និងប្អូនប្រុស តុន ច័ន្ទរិទ្ធិ អ្នកទាំងបីស្ថិតនៅក្នុងការចងចាំដ៏ស្រទន់មួយ។ បងរកនាអត់មានពាក្យអីក្រៅពីពាក្យអរគុណដដែលៗ នៅតែអរគុណដោយក្ដីរំភើបបែបនេះរាល់ពេលដែលនឹកឃើញដល់ថ្ងៃរំភើបមួយនោះ។

ថ្ងៃទី០៧ -០៩ ខែធ្នូឆ្នាំ២០១៨ អនុស្សាវរីយ៍មួយនោះ! ភ្លេចម្ដេចនឹងបានទៅ? ថ្ងៃពិព័រណ៍សៀវភៅកម្ពុជាលើកទី៧ នៅបណ្ណាល័យជាតិនោះអី! ខ្ញុំប្រើឈ្មោះជាអ្នកនិពន្ធទាំងអៀនប្រៀន។ ឱ! អ្នកនិពន្ធគេធ្វើម៉េចខ្លះទៅហ្ន៎! ខ្ញុំមិនចង់ហ៊ានឱ្យអ្នកណាស្គាល់មុខខ្ញុំនោះទេ ខ្ញុំកាន់តែអៀនពេលបងៗអ្នកនិពន្ធផ្សេងទៀតហៅឱ្យអ្នកអានមកស្គាល់មុខខ្ញុំ។ ឱ!ព្រះអើយ ខ្ញុំសមឬមិនសមទេនេះ អ្នកនិពន្ធរតនា! ហិហិ អៀនដល់ហើយ។ ចាំបានថ្ងៃនោះអៀនចុះ អៀនឡើង ដើរចេញពីកម្មវិធីទៅហើយ នរណាមិនដឹងមកចាប់ដៃជាប់ “អ្នកនិពន្ធរតនា! បងជាអ្នកនិពន្ធរតនាមែនទេ?” Fan ខ្ញុំហើយតើនេះ! លាក់មុខលាក់មាត់ប៉ុណ្ណឹងហើយនៅមកចាប់ដៃជាប់ទៀត ខ្ញុំភ័យមិនតិចដែរហ្នឹង។ ម្នាក់នោះជាអ្នកណាដឹងទេ? គឺប្អូនស្រី ង៉ែត គឹមលាង ហ្នឹងហើយ!

អនុស្សាវរីយ៍លើវិថីនិពន្ធអើយ! គួរឱ្យស្ដាប់ស្ដល់ណាស់ ខ្ញុំត្រូវអរគុណដល់អ្នកគាំទ្រទាំងអស់ ទាំងអ្នកដែលមានឈ្មោះនៅក្នុងការរៀបរាប់នេះ និងអ្នកដែលមិនមាន។ អរគុណណាស់ដែលមានវត្តមាននៅក្នុងអនុស្សាវរីយ៍ដ៏ល្អនៅក្នុងជីវិតខ្ញុំ។

រំភើបមួយទៀត មុនរំកិលទៅដល់អនុស្សាវរីយ៍ចុងក្រោយ។ ខ្ញុំជាប់សន្យាខ្លួនឯង មិនដឹងថាហេតុអីខ្ញុំបាននិយាយពាក្យសន្យាមួយនោះ ក៏មិនដឹងថាមានអ្វីមករំឭកស្របពេលដែលសៀវភៅកំពុងតែទទួលបានការគាំទ្រគួរសម "បើវិថីជីវិតអាចចេញជារូបរាងបានមែននោះ ខ្ញុំនឹងមានការបរិច្ចាគទៅមន្ទីរពេទ្យគន្ធបុប្ផា" ។ សន្យារួចហើយ! មិនធ្វើម្ដេចបាន!

កាលពីថ្ងៃទី០៨ខែមករា ២០១៩នេះ ខ្ញុំបានប្រកាសធ្វើសកម្មភាពមនុស្សធម៌មួយដែលខ្ញុំបានដាក់ឈ្មោះថា "អនុស្សាវរីយ៍លើវិថីមនុស្សធម៌" ខ្ញុំបានបរិច្ចាគប្រលោមលោកវិថីជីវិតចំនួន២០ក្បាលដល់មន្ទីរពេទ្យគន្ធបុប្ផា ហើយប្រកាសលក់សៀវភៅទាំង២០ក្បាលនោះ ដោយតម្លៃនៃសៀវភៅនីមួយៗទាំង២០ក្បាលនោះវាអាស្រ័យទៅលើសទ្ធាចិត្តរបស់អ្នកទិញតែប៉ុណ្ណោះ។

កាលនោះខ្ញុំមិនដឹងទេ ថាបើខ្ញុំដាក់លក់ដល់ទៅ២០ក្បាលអីចឹងតើនឹងអាចលក់អស់ទេ? តើមានអ្នកគាំទ្រសកម្មភាពមួយនោះឬអត់? គិតផង បារម្ភផង តែបើជ្រុលសន្យាហើយមិនគួររំលងទេ ទោះមិនមានអ្នកណាឮពាក្យសន្យាមួយនោះក៏ដោយ ពិតទេ? ២០ក្បាលដើម្បីមន្ទីរពេទ្យ

គន្ធបុប្ផា មានអ្នកជួយទិញទេ? មិនអត់ឯណា! អស់២០ក្បាលហើយនៅតែមានអ្នកមកសុំចូលរួមទៀត ហិហិ.. អារម្មណ៍ល្អមែន! ខ្ញុំអើយជួបតែមនុស្សល្អ ពិតជាសំណាងណាស់។ សៀវភៅវិថីជីវិតរបស់ខ្ញុំមានតម្លៃតែ២៨០០០រៀល ឬ៧ដុល្លារប៉ុណ្ណោះនៅលើទីផ្សារ តែមានសប្បុរសជនម្នាក់ហ៊ានឱ្យតម្លៃដល់ទៅ១០០ដុល្លារក្នុងមួយក្បាល ម្នាក់នោះជានរណា? គឺបងប្រុសល្អម្នាក់របស់ខ្ញុំ គាត់ឈ្មោះភារ៉ូ សព្វថ្ងៃគាត់កំពុងរស់នៅសហរដ្ឋអាមេរិកឯណោះ។ ខ្ញុំនៅចាំបានទឹកប្រាក់សរុបដែលបានពីការលក់សៀវភៅទាំងអស់គឺ ៣៩ម៉ឺនរៀល និង ៣៨៥ដុល្លារ។ ទឹកប្រាក់ទាំងនោះ ខ្ញុំនិងអ្នកគាំទ្រប៉ុន្មាននាក់បាននាំយកទៅប្រគល់ជូនមន្ទីរពេទ្យទាំងអស់តែម្តង នៅក្នុងថ្ងៃទី០៨ខែកុម្ភៈឆ្នាំ២០១៩ កាលពីដើមឆ្នាំ។ កាលនោះដែល មនុស្សម្នាក់ ខ្ញុំអនុញ្ញាតឱ្យទិញសៀវភៅបានតែមួយក្បាលប៉ុណ្ណោះ ហើយអ្នកដែលចង់ចូលរួមសកម្មភាពល្អនេះមានលើសពី២០នាក់ទៅទៀត។ តែស្តាយ! ព្រោះតែអ្វីៗបានកំណត់រួចហើយ ខ្ញុំមិនអាចល្មើសច្បាប់ខ្លួនឯងដែរ។ យ៉ាងណាអនុស្សាវរីយ៍មួយនោះធ្វើឱ្យខ្ញុំស្ញប់ស្ញែងណាស់ អាចចាត់ថានោះជាសកម្មភាពមនុស្សធម៌ធំជាងគេរបស់ខ្ញុំ ប្រចាំឆ្នាំ២០១៩ទៅដឹងនេះ?

អាជីពនិពន្ធនាំសំណាងឱ្យខ្ញុំទទួលបានការរាប់អានយ៉ាងកក់ក្ដៅពីប្អូនប្រុស២នាក់ ប្អូនប្រុស តុន ច័ន្ទរិទ្ធិ ម្ចាស់ស្នាដៃ "អ្នកពិតជាពិសេស តោះ! ទៅមុខទៀត"។ នឹកឃើញកាលនោះយើងមានអនុស្សាវរីយ៍ល្អលើកទីមួយជាមួយគ្នាដោយការឈរលក់សៀវភៅស្នាដៃរបស់យើងទាំងពីរនាក់រួមគ្នា ថ្មីថ្មោងដូចគ្នា អៀនប្រៀនដូចគ្នា រិទ្ធិលក់ប្រលោមលោកវិថីជីវិត ទុកឱ្យបងលក់សៀវភៅ អ្នកពិតជាពិសេស តោះ! ទៅមុខទៀត។ រឿងល្អៗមួយនោះវាកើតឡើងកាលពីកម្មវិធីពិព័រណ៍សៀវភៅជាតិលើកទី៧ និងកម្មវិធីអំណានសៀវភៅកាលពីថ្ងៃ០៩ -១១ ខែមិនា ឆ្នាំ២០១៩ នេះ ដែលបានធ្វើឡើងនៅសាលាតិចណូ។ អនុស្សាវរីយ៍ល្អៗនោះភ្លេចម៉េចនឹងបាន?

ចុះម្នាក់ទៀត? អ្នកនិពន្ធក្មេងល្អក់ ធឿនវុទ្ធីនោះហើយ ជាម្ចាស់ស្នាដៃ "យប់ថ្ងៃព្រហស្បតិ៍ អារក្សខ្មៅ និងមួយទៀតដែលកំពុងល្បីខ្លាំងនោះគឺ ទេពច្បុតក្លែងក្លាយ" នេះហើយ។ ពួកយើងបានជួបគ្នាផ្ទាល់តែម្ដងគត់ តែទំនាក់ទំនងបងប្អូនពួកយើងមិនអាស្រ័យលើការជួប ការចរចារនោះឯណា។ ជាបងប្អូននឹងគ្នាបានក៏ព្រោះតែការមានទឹកចិត្តជួយទុក្ខធុរៈគ្នាជារឿយៗ និងការជួយជ្រោមជ្រែងគ្នាទៅ

វិញទៅមកនេះហើយ។ មួយរយៈខ្លីដែលបានស្គាល់ រាប់អានគ្នានេះ បងរតនាពិតជាកក់ក្ដៅដែលបានទទួលការស្រលាញ់រាប់អានពីប្អូនប្រុសទាំងពីរនាក់ណាស់។

ហៃអើយ! មកដល់អនុស្សាវរីយ៍ចុងក្រោយបាត់ទៅហើយ! អ្វីទៅជាអនុស្សាវរីយ៍ចុងក្រោយសម្រាប់ព្រះជន្ម៣៤ឆ្នាំខ្ញុំនេះ? ចាស់ហើយណា៎! និយាយដល់អាយុក៏មានតែពាក្យមួយនេះ ហិហិ..

បងរតនាចាស់ហើយ! មើលរូបថតខ្លួនឯងកាលពីឆ្នាំចាស់ យកមកប្រៀបរូបបច្ចុប្បន្ន មិនបាច់និយាយ! ឃើញថាថយចុះច្រើនហើយ។ ស្អាតនៅតែស្អាត! តែស្អាតបែបចាស់នោះអី! ចាស់ហើយ! ^v^

ចាស់ចុះមិនអីទេ! ដើរកន្លងពេលវេលាយ៉ាងយូរមិនដឹងថាជីវិតមួយនេះនៅសល់អីខ្លះ សង្ខេបៗទៅគឺសល់បានអនុស្សាវរីយ៍ល្អៗប៉ុណ្ណោះឯង។ ទាន់នៅចាំបានក៏ខំសរសេររៀបរាប់ ចងក្រងឱ្យក្លាយទៅជាសៀវភៅអនុស្សាវរីយ៍មួយទុកជាកាដូសម្រាប់ខ្លួនឯងក្នុងឱកាសគម្រប់វ័យ៣៤ឆ្នាំហ្នឹងតែម្ដងទៅ។

អនុស្សាវរីយ៍៣៤ឆ្នាំ ជាអនុស្សាវរីយចុងក្រោយប្រចាំឆ្នាំនេះ តែវានឹងក្លាយជាអនុស្សាវរីយ៍ល្អបំផុតមួយ ជាមោទនៈមួយប្រចាំជីវិតខ្ញុំ។ ខ្ញុំមានបំណងប្រមូលការចងចាំល្អៗទាំងនេះដើម្បីរៀបរៀងជាសៀវភៅសម្រាប់ចែករំលែកទៅដល់អ្នកអានរបស់ខ្ញុំ ហើយសំខាន់មួយទៀត នៅតែចង់ឱ្យការចងចាំទាំងអស់មានការពាក់ព័ន្ធនឹងទង្វើរមនុស្សធម៌ដដែល។ ដឹងទេ? សៀវភៅមួយចំណងជើងនេះអាចហៅថាជា limited edition ខ្ញុំបានស្នើរោងពុម្ពសុំធ្វើការបោះពុម្ពត្រឹមតែ៥០០កូពីតែប៉ុណ្ណោះ ដោយនេះជាសៀវភៅកំណត់ហេតុផង ខ្ញុំមិនសន្យាថានឹងមានការបោះពុម្ពបន្ថែមទៀត ឬអត់ដែរទៅថ្ងៃអនាគត គ្រាន់តែដឹងថាចិត្តនេះ ចង់ធ្វើវាត្រឹមតែប៉ុណ្ណឹង។ បើមិនមានកាលៈទេសៈណា ស្នើរសុំឱ្យមានការផ្លាស់ប្តូរចិត្តទេ មួយចំណងជើងនេះ នាងខ្ញុំពេញចិត្តឱ្យមានត្រឹមតែ៥០០កូពីរហូតទៅ។ ចំនួន៥០កូពី នៃ៥០០កូពីនេះ នឹងប្រើដើម្បីចែកជូនទៅមនុស្សជាទីស្រលាញ់គោរពមួយចំនួន និងជាការបរិច្ចាគតិចតួចតែប៉ុណ្ណោះ ចំនួនដែលសេសសល់នឹង រក្សាទុកជាអនុស្សាវរីយ៍សម្រាប់ខ្លួនឯង។ ៤៥០កូពីជាភាគដែលសម្រាប់ដាក់លក់នៅលើទីផ្សារ ដោយរំពឹងដកប្រាក់១ដុល្លាពីការលក់បានពីសៀវភៅនីមួយៗនេះដើម្បីយកទៅបរិច្ចាគជូនមន្ទីរពេទ្យគន្ធបុប្ផាម្តង

ទៀត។ បើក្តីរំពឹងមិនខកបំណងទេ ខ្ញុំនឹងទទួលបានទឹកប្រាក់៤៥០ដុល្លារយកទៅជូនដល់មន្ទីរពេទ្យគន្ធបុប្ផាមិនខាន។

តួរអក្សរមួយតួរៗ រត់ពេញលើកញ្ចក់កុំព្យូរទ័រ ជាមួយនិងអារម្មណ៍ស្ទួរនាំ និងបារម្ភ។ តើអ្នកអានរបស់ខ្ញុំយល់ចិត្តខ្ញុំទេ?

សៀវភៅតូចមួយក្បាលនេះមិនដឹងថាមានគុណតម្លៃអីនោះទេ! បើអានហើយតើវាអាចជួយអ្វីដល់អ្នកអានជាទីស្រលាញ់របស់ខ្ញុំបានខ្លះ? ការពិតបើគ្រាន់តែអានឱ្យតែដឹងរឿងដែលបានកើតឡើងក្នុងជីវិតរបស់ខ្ញុំនោះគឺពិតជាខាតលុយក្នុងការទិញសៀវភៅមួយក្បាលនេះហើយ!

អ្នកប្រហែលជាចាប់អារម្មណ៍ជក់ចិត្តអានតែជីវិតដែលមានបទពិសោធន៍ជូរចត់ អានដល់ហូរទឹកភ្នែក។ ព្រោះជីវភាពបែបនោះវាជាកម្លាំងជម្រុញដ៏ខ្លាំងក្លាឱ្យមនុស្សអាចបង្ហាញពីភាពរឹងមាំ និងឈរនៅលើភាពជោគជ័យដោយមោទនៈ។

តែបើអានហើយសាកគិតបន្តិច អនុស្សាវរីយ៍៣៤ឆ្នាំរបស់អ្នកនិពន្ធរតនា អានហើយគួរឱ្យច្រណែនខ្លះទេ? រៀបរាប់តែពីអ្វីដែលទទួលបាន និងភាពសមបំណង តិចឃើញតែរៀបរាប់រឿងល្អៗច្រើនពេកនោះ ល្បួចជ្រេញទៅចុះ!

ជីវិតដែលជោគជ័យមិនចាំបាច់ត្រូវតែរៀបរាប់ពីភាពជូរចត់ដែលធ្លាប់មានទេ។ ជីវិតនៅលើផែនដីនេះ តើ

មានជីវិតមួយណាដែលស្គាល់តែសុខរហូតនោះ? នរណាមិនធ្លាប់យំ? នរណាមិនធ្លាប់កើតទុក្ខ? ខាងក្រោយអនុស្សាវរីយ៍ល្អៗដែលខ្ញុំបានរៀបរាប់នេះ ដឹងទេថាមានការយំយែកកើតទុក្ខអ្វីខ្លះនោះ។ បើសរសេរបន្ថែមរឿងទុក្ខសោកទាំងឡាយនោះ ៣៤ឆ្នាំកន្លងមកនេះ មិនដឹងថាត្រូវប្រើក្រដាសប៉ុន្មានទំព័រនោះទេ។

អនុស្សាវរីយ៍! គឺជាការចងចាំមួយ ការចងចាំ! វាគួរតែជារឿងល្អៗ គួរតែជារឿងដែលធ្វើឱ្យមនុស្សមានអារម្មណ៍ល្អ។ រឿងមិនល្អ មិនសប្បាយចិត្តរំឭកធ្វើអី?

ចង់សូនជីវិតមួយដែលពោរពេញទៅដោយភាពរីករាយ អ្នកគប្បីរៀនបំភ្លេចរឿងដែលមិនសប្បាយចិត្ត ហើយរក្សាការចងចាំល្អ។ ឱ! បើភាពជោគជ័យដែលមាននេះបានមកតែពីក្តីស្រលាញ់ និងអនុស្សាវរីយ៍នៃស្នាមញញឹម តើជីវិតនោះស្រស់ស្រាយប៉ុនណាទៅ? នរណាអើយ! ទទួលបានជីវិតនោះតើមានសំណាងម្តេចទៅ?

ព្រោះតែហេតុផលខាងលើនោះ ខ្ញុំតែងប្រើពាក្យមួយឱ្យខ្លួនឯង “ខ្ញុំមិនពូកែទេ! ខ្ញុំគ្រាន់តែសំណាង” ។ ខ្ញុំសំណាងដែលបានកើតនៅក្នុងគ្រួសារដែលកក់ក្តៅមួយ

មានម៉ាក់ប៉ាដែលស្រលាញ់ថ្នាក់ថ្នម មានបងប្រុស បងស្រីស្រលាញ់យល់ចិត្ត មានប្អូនប្រុសដែលចាំធ្វើជាអង្គរក្ស មានមិត្តល្អៗជាច្រើនទៀតដែលចាំតែយោគយល់ និងកំដររាល់ពេលដែលខ្ញុំត្រូវការ។ ចង់បានអ្វីទៀត? ជីវិតរបស់ខ្ញុំរស់មកដល់អាយុ៣៤ឆ្នាំនេះ ខ្ញុំសែនស្កប់ស្កល់នូវអ្វីដែលកំពុងមាន ហើយកិច្ចការដែលខ្ញុំត្រូវធ្វើបន្តគឺខំរក្សាអ្វីដែលល្អៗនោះឱ្យនៅជាមួយខ្ញុំឱ្យបានយូរ និងរៀនត្រៀមចិត្តនិយាយពាក្យថា " **លា**" នៅពេលណាមួយដែលវាចង់ទៅ។

អានរឿងល្អៗដែលកើតឡើងក្នុងជីវិតរបស់ខ្ញុំ ខ្ញុំមិនរំពឹងឱ្យអ្នកអានរបស់ខ្ញុំគិតថាជាមនុស្សបែបនេះ ឬបែបនោះមួយក្នុងផ្លូវអវិជ្ជមានឡើយ។

សូមគិតដល់ថា ពេលដែលខ្ញុំរំឭកពីរឿងល្អក្នុងវគ្គនីមួយៗនៃជីវិតរបស់ខ្ញុំនេះ គឺចង់ឱ្យអ្នកអានចាប់អារម្មណ៍នឹកដល់វគ្គល្អៗនៃជីវិតរបស់អ្នកដូចគ្នាដែរ។ បំភ្លេចរឿងដែលធ្លាប់យំ ហើយគិតដល់រឿងដែលធ្លាប់សើច។ មិនអាចសរសេរបានជាសៀវភៅក៏ត្រឹមអាចរក្សាទុកនៅក្នុងចិត្តរបស់អ្នក ហើយរំឭកប្រាប់ខ្លួនឯងរហូតទៅ ពិសេសរាល់ពេលដែលអ្នកទំនេរ។ មួយឆាកជីវិតនេះ តើមានពេលណាខ្លះដែលអ្នកបានសើច?

តើមានរឿងហេតុអ្វីខ្លះកើតឡើងកន្លងមក ហើយធ្វើឱ្យអ្នកយល់ថាជីវិតរបស់អ្នកមានក្តីសុខយ៉ាងនេះ?

**"ឆាកជីវិតមនុស្សម្នាក់ៗ មិនដឹងថាវែងឬខ្លីប៉ុនណាទេ តែអ្វីដែលអ្នកគួរធ្វើគឺ រក្សាការចងចាំល្អៗ"**

# រូបថតអនុស្សាវរីយ៍

## រូបនេះថតកាលពីថ្ងៃទី២៦ខែសីហាឆ្នាំ២០១៩

រូបថតមួយសន្លឹកនេះហើយ ដែលនាំឱ្យចិត្តខ្ញុំរឭកដល់អនុស្សាវរីយ៍ជាច្រើន ហើយខំសរសេររៀបរាប់រហូតទាល់តែបានសៀវភៅតូចមួយក្បាលនេះ។





រូបមួយនេះ ថតបានពេលម៉ាក់កំពុងបញ្ចុកបាយប្អូនប្រុស របស់ខ្ញុំនៅមុខផ្ទះ ពេលគាត់កំពុងលក់ដូរផង។ យករូបប្អូន ជំនួសឱ្យខ្ញុំ ព្រោះកាលម៉ាក់នៅបញ្ចុកបាយខ្ញុំ គ្រួសារយើង មិនទាន់មានម៉ាស៊ីនថតរូបប្រចាំគ្រួសារទេ។ តែយ៉ាងណា កាយវិកាទន់ភ្លន់របស់ម៉ាក់ មិនធ្លាប់ផ្លាស់ប្តូរទេ មិនថាបញ្ចុក បាយកូនម្នាក់ណាក៏ដោយ នេះជាភាពកក់ក្តៅមួយ ជា សំណាងមួយក្នុងជីវិតខ្ញុំ ដែលទទួលបានកាយវិការថ្នមថ្នាក់ បែបនេះអំពីម៉ាក់។



នេះជារូបថតកាលចូលឆ្នាំខ្មែរ ក្នុងឆ្នាំ១៩៩៧

កាលនោះខ្ញុំទើបតែអាយុ១២ឆ្នាំទេ។ មើលចុះ! ក្រោយកៅអីដែលប្អូនខ្ញុំអង្គុយនោះជាផ្លូវចេញចូលក្នុងផ្ទះយើង ក៏ជាកន្លែងញ៉ាំបាយថ្ងៃត្រង់ដែលខ្ញុំបានរៀបរាប់ដែរ។ ផ្ទះខ្ញុំកាលនោះគឺចង្អៀតបែបនេះឯង។ នៅខាងកៅអីដែលប្អូនខ្ញុំអង្គុយថតនោះដឹងទេ? ជាកន្លែងដែលខ្ញុំចង់អង្គុយថត តែសូម្បីតែកន្លែងអង្គុយក៏គាត់ដណ្តើមខ្ញុំដែរ សូម្បីតែថតរូបក៏អ៊ីចឹងឱ្យគាត់ថតម្នាក់ឯងហើយ ក៏គាត់នៅតែមកទារថតជាមួយខ្ញុំ គឺថាដណ្តើមរហូតអ៊ីចឹងឯង ហិហិ..



មួយគ្រួសារយើងមាន៥នាក់ កាលពួកយើងនៅតូចៗម៉ាក់ប៉ាជាអ្នករកស៊ី ម្ល៉ោះហើយពួកយើងមិនងាយបានដើរលេងជុំគ្នាទេ កាន់តែកម្រមានរូបថតជុំគ្នា។ រូបនេះតាំងពីខ្ញុំរៀនថ្នាក់ទី១០ មិនចាំថាថតនៅឆ្នាំ១៩៩៩ ឬ២០០០នោះទេ។ ឃើញនាឡិកាតូចដែលខ្ញុំពាក់នោះទេ? គឺមួយគូដែលប៉ាទិញឱ្យពួកយើងនោះហើយ មួយនេះជារបស់បងស្រីទេ ខ្ញុំខ្ចីគាត់មកពាក់ឱ្យត្រូវឈុតខ្ញុំប៉ុណ្ណោះ នាឡិកានោះបងស្រីក៏ស្រលាញ់ណាស់ដែរ បងស្រីពាក់រាប់ឆ្នាំ ពាក់ទាល់តែខូច។



រូបមួយសន្លឹកនេះថតនៅក្នុងព្រះបរមរាជវាំងកាលពីឆ្នាំ២០១០ ឬ២០១១ កាលនោះម៉ាឡែនឧស្សាហ៍បានមកលេងខ្ញុំនៅភ្នំពេញណាស់ ខ្ញុំមានឱកាសឱ្យគាត់បានជួបស្និទ្ធស្នាលនឹងមិត្តល្អរបស់ខ្ញុំពីរនាក់ទៀតគឺ មុនី និងប៉ូឡែត។



មួយសន្លឹកនេះចាំបានថតកាលពីឆ្នាំ២០១១ កាលនោះខ្ញុំទើបរៀនថ្នាក់ទី១១។ ថ្នាក់បម្រុងប្រឡងបាក់ឌុប សាលាឧស្សាហ៍ឱ្យយើងចុះទស្សនកិច្ចណាស់។ មួយសន្លឹកនេះ ខ្ញុំនិងមិត្តរួមថ្នាក់ និងលោកគ្រូ អ្នកគ្រូថតរូបជុំគ្នានៅសារៈមន្ទីរជាតិ។



Foundation Children's hospital Kantha Bopha,
Dr. med. Beat Richner

Kantha Bopha Foundation

DONATION

Ladies, Gentlemen : Miss SRONG CHANRATANA

Company : ( RATANA )

Address :

Donation amount : 345 USD
39000 R

We thank you very much for your kind support
in order to save the children lives.

Phnom Penh - ~~Siem Reap~~ - Kingdom of Cambodia

Date : 08.02 2019

Receiver Donor

Dr. DENIS LAURENT
COO Cambodia

KANTHAK BOPHA FOUNDATION



មួយសន្លឹកនេះជាតំណាងនៃការបរិច្ចាគទឹកប្រាក់ដែលបានពីការលក់សៀវភៅប្រលោមលោកវិថីជីវិត ជូនដល់មន្ទីពេទ្យគន្ធបុប្ផា។ ទឹកប្រាក់សរុបដែលបានពីការលក់សៀវភៅទាំងអស់គឺ ៣៩មុឺនរៀល និង ៣៤៥ដុល្លារ។



ខ្ញុំប៉ងចង់បានគំនូររូបខ្លួនឯងមួយផ្ទាំងគឺការពិត។ តែខ្ញុំចង់បានពីទឹកដៃដ៏ប្រណិតដែលអាចគូររូបខ្ញុំឱ្យដូចរូបពិត តែ! ស្រាប់តែខ្ញុំបានទទួលគំនូរមួយផ្ទាំងដែលគូរដោយទឹកចិត្តដ៏ប្រណិត ការគូរនិងផាត់ដែលរចនាដោយក្ដីគោរពនិងការស្រលាញ់ វាពិសេសណាស់សម្រាប់ខ្ញុំ មានតែពាក្យថាអរគុណប្អូនស្រីដែលប្រើនាម ពណ៌ខ្មៅ។

**អនុស្សាវរីយ៍៣៤ឆ្នាំរបស់អ្នកនិពន្ធតែនា អានហើយ គួរឱ្យច្រណែនខ្លះទេ?**